**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាខួប២០ឆ្នាំមណ្ឌលនិស្សិតកាតូលិកកម្ពុជា**
**ភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៩**

**រស់នៅដោយបម្រើនិងសន្ទនានៅក្នុងវប្បធម៌**

**អត្ថបទទី១៖ បទចម្រៀងព្រះបាទសាឡូម៉ូន ២,៨-១៤**

ម្ចាស់ជីវិតរបស់ខ្ញុំរត់លឿនដូចក្ដាន់ ឬប្រើសស្វាវ មើល៍គាត់ឈរនៅខាងក្រៅផ្ទះ គាត់អើតតាមបង្អួច ហើយពិនិត្យមើលតាមចម្រឹង។ បច ២,៩

**ដំណឹងល្អ៖ លូកា ១,៣៩-៤៥**

កាលខ្ញុំបានឮពាក្យជម្រាបសួររបស់នាង ស្រាប់តែកូននៅក្នុងផ្ទៃខ្ញុំបម្រះឡើងដោយអំណរសប្បាយ។ លក ១,៤៤

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាថ្ងៃឱឡារិកសម្រាប់ព្រះសហគមន៍កាតូលិកកម្ពុជា នៅក្នុង២០ឆ្នាំកន្លងមកបានយកចិត្តទុកដាក់ដើម្បីណែនាំឲ្យកូនយើងបានទទួលការអប់រំ ឲ្យមានចំណេះដឹង ឲ្យមានសីលធម៌ ឲ្យមានរបៀបរស់នៅនៅក្នុងសង្គមយ៉ាងល្អ។ ឆ្នាំ១៩៩៨ យើងបានចាប់ផ្ដើមបង្កើតមណ្ឌលនិស្សិត យើងបានតស៊ូច្រើនមុនយើងមានមណ្ឌលនិស្សិតយ៉ាងស្អាតនេះ ដោយយល់ថាការអប់រំជាអ្វីដែលសំខាន់សម្រាប់បច្ចុប្បន្ននិងអនាគត។ ២០ឆ្នាំនេះ យើងមានជិត៥០០នាក់ដែលបានទទួលសញ្ញាបត្រ ដែលបានទទួលការអប់រំនៅក្នុងមណ្ឌលនិស្សិតយើង។ ២០ឆ្នាំ ដែលយើងបានយកចិត្តទុកដាក់ដើម្បីណែនាំឲ្យចូលនៅក្នុងជីវិតជាជនជាតិខ្មែរផង ជីវិតជាគ្រីស្តបរិស័ទម្នាក់ម្ដងផង និងជាជីវិតមនុស្សដែលត្រៀមខ្លួនដើម្បីបង្កើតគ្រួសារផង។

អត្ថបទដែលយើងស្ដាប់ថ្ងៃនេះ “**នាងពិតជាមានសុភមង្គលមែន ព្រោះនាងបានជឿព្រះបន្ទូលដែលព្រះអម្ចាស់ប្រាប់នាងមុខជាបានសម្រេចមិនខាន**” អំណរសប្បាយរបស់យើង សុភមង្គលរបស់យើងមាននៅពេលយើងជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ពេលយើងប្រារព្ធ២០ឆ្នាំនៃមណ្ឌលនិស្សិត យើងធ្វើនៅក្នុងរដូវរង់ចាំព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលកំពុងចាប់កំណើតជាមនុស្សដើម្បីធ្វើដំណើរជាមួយយើងពីមួយថ្ងៃទៅមួយថ្ងៃ។ យើងនឹកឃើញដល់ព្រះយេស៊ូដែលបានចាប់កំណើតជាមនុស្ស២០០០ឆ្នាំ ព្រះយេស៊ូបានធ្វើដំណើរជាមួយមនុស្សលោកដើម្បីឲ្យគេចូលនៅក្នុងគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ ហេតុនេះហើយ ពេលយើងមើលស្នាដៃរបស់យើងនៅក្នុង២០ឆ្នាំកន្លងមក ដូចជាយើងចូលនៅក្នុងប្រវត្តិសាស្ត្រនៃការសង្គ្រោះរបស់ព្រះជាម្ចាស់លើទឹកដីប្រទេសកម្ពុជា។ ឲ្យយើងនឹកឃើញ នៅក្នុង២០ឆ្នាំយើងបានណែនាំនៅក្នុងមណ្ឌលនិស្សិតយើង នៅប្រទេសកម្ពុជាយើង គឺឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាប់កំណើតជាមនុស្សយ៉ាងជាក់ស្ដែង។

ដូច្នេះ ពីជំនាន់ទី១រហូតដល់ជំនាន់ទី២២បច្ចុប្បន្ននេះ ឲ្យយើងនឹកឃើញជីវិតរបស់យើងពីដើម ឲ្យយើងនឹកឃើញព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលបានចាប់កំណើតជាមនុស្ស នៅក្នុងជីវិតរបស់យើង នៅក្នុងការងាររបស់យើង នៅក្នុងសេចក្តីសុខយើង នៅក្នុងទុក្ខលំបាករបស់យើង។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចាប់កំណើតជាមនុស្ស ដើម្បីធ្វើដំណើរជាមួយយើងឲ្យយើងរីកចម្រើនតទៅទៀត។ ២០ឆ្នាំ ព្រះសហគមន៍របស់យើង សង្គមរបស់យើងបានប្រែប្រួលយ៉ាងច្រើន របៀបដែលរស់នៅក្នុងសង្គមក៏ប្រែប្រួលដែរ។ យើងត្រូវការទទួលស្គាល់បច្ចុប្បន្នដែលយើងរស់នៅសព្វថ្ងៃ ពេលយើងនិយាយអំពីព្រះយេស៊ូចាប់កំណើតជាមនុស្សមិនណែនាំឲ្យយើងត្រលប់ទៅ២០០០ឆ្នាំមុនទេ មិនណែនាំឲ្យយើងទៅប្រកាសដំណឹងល្អដូចព្រះយេស៊ូ២០០០ឆ្នាំមុនទេ យើងមានរបៀបថ្មី យើងមានឧបករណ៍ថ្មី។ ប៉ុន្តែ ចិត្តគំនិតរបស់មនុស្ស២០០០ឆ្នាំមុននិងបច្ចុប្បន្ននេះ នៅតែសាងសង់ដដែល យើងនៅតែមានទុក្ខលំបាកដដែល។ ទោះបី យើងមានការអភិវឌ្ឍន៍យ៉ាងច្រើន មានការងារធ្វើច្រើន មានជីវភាពល្អជាងមុន មានចំណេះដឹងច្រើនជាងមុន តែយើងដឹងថារបៀបដែលយើងត្រូវការកសាងចិត្តគំនិតរបស់យើង នៅតែជាអាទិភាពសម្រាប់ជីវិតរបស់យើង។

៣ឆ្នាំខាងមុខ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញយើងចូលនៅក្នុងខួប៥០ឆ្នាំ នៃក្រុមលោកអភិបាលនៅទ្វីបអាស៊ី។ សម្រាប់និស្សិតពីជំនាន់ទី១រហូតដល់ជំនាន់ទី២២នេះ យើងត្រូវការចូលនៅក្នុងនេះដែរ យើងមានបីចំណុចដែលយើងត្រូវចាប់អារម្មណ៍ ដើម្បីមើលនៅខាងមុខនេះក្នុងជីវិតរបស់យើង **តើយើងបន្តរស់នៅជាគ្រីស្តបរិស័ទមួយរូប ជាជនជាតិខ្មែរមួយរូបដូចម្តេចដើម្បីបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់?**

**ចំណុចទីមួយ ការអភិវឌ្ឍន៍ តើយើងធ្វើដូចម្តេចដើម្បីបម្រើ?** បម្រើអ្នកក្រីក្រ បម្រើប្រជាជន បម្រើអ្នកតូចតាច នៅក្នុងព្រះសហគមន៍ផង នៅក្នុងសង្គមផង ដើម្បីឲ្យព្រះសហគមន៍និងសង្គមរីកចម្រើនយ៉ាងពិតប្រាកដ។ សម្រាប់យើងដែលរស់នៅក្នុងសង្គមបច្ចុប្បន្ននេះ យើងត្រូវការគិតពិចារណានៅក្នុងសង្គមនេះ ខ្ញុំចង់អភិវឌ្ឍន៍អ្វីខ្លះ សម្រាប់យើងជាគ្រីស្តបរិស័ទយើងត្រូវការយកអាទិភាពអ្វីខ្លះ។ អាទិភាពរបស់យើង គឺយើងធ្វើដូចម្តេចដើម្បីឲ្យសង្គមរបស់យើងចេះមើលឃើញបងប្អូនដែលអភិវឌ្ឍន៍មិនទាន់គេ ចេះមើលឃើញបងប្អូនដែលគ្មានទីពឹងដើម្បីមានទីពឹងដូចគេឯង។ នៅមណ្ឌលបងប្រុសមេត្តាករុណាចោមចៅ គាត់បានទទួល៥៣នាក់នៅក្នុងមណ្ឌលគាត់ មានទាំងកុមារ យុវជន លោកពូ លោកតា ដែលដើរមិនរួច ដែលនិយាយមិនកើត ដែលមានស្មារតីមិនប្រក្រតី របៀបដែលបងប្រុសថែរក្សាជាសញ្ញាមួយដែលណែនាំឲ្យយើងត្រូវតែគិតពិចារណា អំពីរបៀបដែលយើងចង់អភិវឌ្ឍន៍សង្គមរបស់យើង។

**ចំណុចទីពីរ ការសន្ទនា** បច្ចុប្បន្ននេះយើងមានឧបករណ៍យ៉ាងច្រើន ដើម្បីបង្កើតទំនាក់ទំនង ប៉ុន្តែមិនមែនមានន័យថាយើងបានសន្ទនាគ្នាទេ។ យើងបង្កើតទំនាក់ទំនងជាមួយគ្នាតាមប្រអប់សារក្នុងទូរស័ព្ទដៃក៏បាន ប៉ុន្តែយើងមិនបានចូលនៅក្នុងការសន្ទនាជាមួយគ្នា ដោយនិយាយគ្នាដោយផ្ទាល់។ ប្រសិនបើ ប្តីប្រពន្ធចាប់ផ្តើមនិយាយគ្នាតែតាមទូរស័ព្ទដៃ បន្តិចម្តងៗគ្រួសារយើងលែងមានភាពស្និទ្ធស្នាលអស់ហើយ។ ប្រសិនបើ យើងនិយាយគ្នានិងមានទំនាក់ទំនងជាមួយគ្នាតាមទូរស័ព្ទដៃតែប៉ុណ្ណឹង យើងមិនបានចូលនៅក្នុងការសន្ទនាដើម្បីសម្រុះសម្រួលគ្នាទេ។ ការសន្ទនាណែនាំឲ្យយើងសម្រុះសម្រួលយ៉ាងច្រើន ការសន្ទនាណែនាំឲ្យយើងយល់ចិត្តគ្នាយ៉ាងច្រើន ការសន្ទនារវាងគ្នានឹងគ្នា ការសន្ទនារវាងសង្គមនឹងព្រះសហគមន៍ ការសន្ទនារវាងសាសនានឹងសាសនា យើងត្រូវយកការសន្ទនាជាអាទិភាព។ ឲ្យយើងថែរក្សាការសន្ទនាដោយផ្ទាល់ នេះសំខាន់ណាស់ដើម្បីធ្វើដំណើរជាមួយគ្នាយ៉ាងជិតស្និទ្ធ។

**ចំណុចទីបី វប្បធម៌** ក្នុង២០ឆ្នាំវប្បធម៌បានប្រែប្រួលទាំងអស់ របៀបរស់នៅ របៀបទំនាក់ទំនង ឲ្យយើងបើកភ្នែកដើម្បីយល់ថាវប្បធម៌មិនមែនតែក្បាច់រចនា របាំប្រពៃណី... វប្បធម៌គឺអ្វីៗទាំងអស់ដែលណែនាំឲ្យយើងស្គាល់ថាខ្ញុំជាជនជាតិខ្មែរមួយរូប វប្បធម៌ជាអ្វីៗទាំងអស់ដែលបង្ហាញអំពីអត្តសញ្ញាណរបស់យើងបច្ចុប្បន្ននេះ។ ការចងចាំដើម្បីយល់អំពីអត្តសញ្ញាណបច្ចុប្បន្ននេះ ការចងចាំដើម្បីយល់អំពីគោលដៅសម្រាប់ប្រទេសយើង សម្រាប់ជីវិតរបស់យើងបច្ចុប្បន្ននេះដែរ។ ដូច្នេះ សម្រាប់និស្សិតក្តី សម្រាប់គ្រីស្តបរិស័ទក្តី សម្រាប់បូជាចារ្យក្តី យើងចូលនៅក្នុងវប្បធម៌បច្ចុប្បន្ននេះដើម្បីធ្វើដំណើរជាមួយគ្នា ដើម្បីបម្រើ ដើម្បីបង្កើតការសន្ទនា។ បើយើងមិនយល់ចិត្តគ្នាយើងមិនអាចបម្រើបានទេ បើយើងមិនយល់វប្បធម៌យើងអាចបម្រើខុស។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងធ្វើដំណើរនៅក្នុងវប្បធម៌បច្ចុប្បន្ននេះ យើងបង្កើតការសន្ទនាយ៉ាងច្បាស់លាស់ យើងបម្រើអស់ពីដួងចិត្ត ណែនាំឲ្យយើងយល់ថាយើងអាចបន្តបង្កើតព្រះសហគមន៍របស់យើង បង្កើតធនធានមនុស្សតទៅទៀត។ នេះជាមោទនភាពរបស់ព្រះសហគមន៍កាតូលិកកម្ពុជា សព្វថ្ងៃយើងមានរាប់ពាន់នាក់ដែលជាលោកគ្រូអ្នកគ្រូ ដែលជាបុគ្គលិកសិក្សា ដើម្បីបង្កើតធនធានមនុស្ស។ យើងមានរោងចក្រផលិតធនធានមនុស្សយ៉ាងធំទូទាំងប្រទេស ដើម្បីបង្កើតធនធានមនុស្សសម្រាប់ធ្វើការនៅក្នុងប្រទេសកម្ពុជា ដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជា ដើម្បីកសាងក្រុមគ្រួសារផ្ទាល់ខ្លួនឲ្យក្លាយជាគ្រួសារសុខសាន្ត ដែលណែនាំឲ្យប្រទេសយើងសុខសាន្ត។ ព្រះសហគមន៍កាតូលិកកម្ពុជា រស់នៅក្នុងវប្បធម៌ នៅក្នុងអរិយធម៌ ចាក់ឬសនៅក្នុងសង្គមបច្ចុប្បន្ននេះ ដើម្បីជួយឲ្យយើងទាំងអស់គ្នាអាចរួមរស់នៅក្នុងអំណរសប្បាយ និងរស់នៅក្នុងពន្លឺមកពីព្រះគ្រីស្ត ដោយសារគោលដៅរបស់យើងគឺកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់លើផែនដីនេះ។ អាម៉ែន៕